ក្រសួងមហាផ្ទៃ
គម្រោងលើកកម្ពស់ជីវភាពប្រជាជនក្រីក្រ( លាភ )
Livelihood Enhancement & Association of the Poor( LEAP )
IDA Credit No. 5960-KH
WORLD BANK GROUP

លេខ: ០០៣៥/១៥

# សេចក្តីជូនដំណឹង
## ស្តីពីការជ្រើសរើសមន្ត្រីសម្របសម្រួលឃុំ-សង្កាត់
## នៃគម្រោងលើកកម្ពស់ជីវភាពប្រជាជនក្រីក្រ (LEAP)

គម្រោងលើកកម្ពស់ជីវភាពប្រជាជនក្រីក្រ (LEAP) ត្រូវសម្របសម្រួល និងអនុវត្ត ដោយក្រសួងមហាផ្ទៃ ជាមួយ រដ្ឋបាលសាលាខេត្តសៀមរាប សាលារាជធានីភ្នំពេញ និង ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ គោលបំណងនៃការបង្កើតគម្រោង (PDO) គឺដើម្បីបង្កើនលទ្ធភាពរបស់គ្រួសារក្រីក្រ និងជនងាយរងគ្រោះក្នុងសហគមន៍ដែលបានជ្រើសរើស ក្នុងការទទួលបាននូវសេវាហិរញ្ញវត្ថុសំរាប់ ឱកាសបង្កើតប្រាក់ចំណូល និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ព្រមទាំងដើម្បីផ្តល់ការឆ្លើយតបភ្លាមៗ និងមានប្រសិទ្ធភាព ក្នុងករណីមានវិបត្តិ ឬគ្រោះអាសន្ន។ គោលបំណងនេះនឹងសម្រេចបានតាមរយៈ៖ (ក) ការបង្កើតក្រុមជួយខ្លួនឯង (SHGs) ក្រុមសន្សំប្រាក់ និងឥណទាន ក្រុមអ្នកផលិត (PG) សហគមន៍កសិកម្ម និងក្រុមមនុស្សផ្សេងៗរួមទាំងអង្គការក្រៅរដ្ឋាភិបាល (ខ) ការផ្តល់ការកសាងសមត្ថភាព និងការបណ្តុះបណ្តាលដល់អ្នកទទួលផលដើម្បីលើកកម្ពស់ឱកាសរកប្រាក់ចំណូលរបស់ពួកគេ (គ) ការបង្កើតតំណភ្ជាប់វិស័យឯកជនដើម្បីលើកកម្ពស់ និងពង្រីកឱកាសទីផ្សារ (ឃ) ការកំណត់អត្តសញ្ញាណក្នុងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ និងសេដ្ឋកិច្ចតាមរយៈសហគមន៍ដើម្បីជួយលើកកម្ពស់ជីវភាពរស់នៅ និងផលិតភាពសេដ្ឋកិច្ចរបស់ប្រជាជនក្រីក្រ។

នៅខេត្តសៀមរាបគម្រោងនេះមានគោលបំណងដោះស្រាយតម្រូវការរបស់គ្រួសារជនងាយរងគ្រោះនៅក្នុងឃុំ/សង្កាត់ចំនួន ៨៧ តាមរយៈការចូលរួម។ ដោយសារប្រភពប្រាក់ចំណូលដ៏ច្រើនសម្រាប់គ្រួសារក្រីក្រនៅតាមជនបទទាំងនេះគឺមកពីវិស័យកសិកម្ម ការចិញ្ចឹមសត្វ និងជលផល គម្រោងនេះទទួលបានការគាំទ្របច្ចេកទេសពីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទតាមរយមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្ត និងអ្នកផ្តល់សេវាកម្មបច្ចេកទេសផ្សេងទៀត។

គម្រោងលើកកម្ពស់ជីវភាពប្រជាជនក្រីក្រ(LEAP)ត្រូវការជ្រើសរើសមន្ត្រីសម្របសម្រួលឃុំ/សង្កាត់ជំហានទី១ចំនួន ១៨រូប ដែលមានដូចខាងក្រោម៖

| ល.រ | ក្រុង/ស្រុក | សង្កាត់/ឃុំ | ចំនួន |
|---|---|---|---|
| ០១ | ក្រុងសៀមរាប | សង្កាត់ចុងឃ្នៀស | ០១រូប |
| ០២ | | សង្កាត់ក្របីរៀល | ០១រូប |
| ០៣ | ស្រុកពួក | ឃុំពោធិ៍ទ្រាយ | ០១រូប |
| ០៤ | | ឃុំល្វា | ០១រូប |
| ០៥ | ស្រុកក្រឡាញ់ | ឃុំកំពង់ថ្កូវ | ០១រូប |
| ០៦ | | ឃុំសំបួរ | ០១រូប |
| ០៧ | ស្រុកស្រីស្នំ | ឃុំស្លែងស្ពាន | ០១រូប |
| ០៨ | | ឃុំក្លាំងហាយ | ០១រូប |
| ០៩ | ស្រុកអង្គរធំ | ឃុំស្វាយចេក | ០១រូប |

| ល.រ | ស្រុក | ឃុំ | ចំនួន |
|---|---|---|---|
| ១០ | ស្រុកអង្គរធំ | ឃុំលាងដៃ | ០១រូប |
| ១១ | ស្រុកស្វាយលើ | ឃុំតាសៀម | ០១រូប |
| ១២ | | ឃុំខ្នងភ្នំ | ០១រូប |
| ១៣ | ស្រុកជីក្រែង | ឃុំជីក្រែង | ០១រូប |
| ១៤ | | ឃុំអណ្តូងសំណរ | ០១រូប |
| ១៥ | ស្រុកសូទ្រនិគម | ឃុំដានរុន | ០១រូប |
| ១៦ | | ឃុំកំពង់ឃ្លាំង | ០១រូប |
| ១៧ | ស្រុកប្រាសាទបាគង | ឃុំបល្ល័ង្គ | ០១រូប |
| ១៨ | | ឃុំកំពង់ភ្លុក | ០១រូប |

I. **លក្ខណៈសម្បត្តិក្នុងការជ្រើសរើស**

- បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ
- មានលំនៅដ្ឋាននៅក្នុងឃុំគោលដៅ និងមានឆន្ទៈក្នុងការគាំទ្រដល់សកម្មភាពគម្រោងនៅក្នុងឃុំ/សង្កាត់
- មានបទពិសោធន៍ធ្វើការជាមួយគម្រោងមូលដ្ឋាន របស់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និង/ ឬ គម្រោងអភិវឌ្ឍដទៃទៀត ស្ម័គ្រចិត្តឬទទួលប្រាក់ខែ
- មានសមត្ថភាពសរសេរនិងអាន (ដើម្បីតាមដានសកម្មភាពហិរញ្ញវត្ថុរបស់ក្រុមសហគមន៍) លទ្ធភាពរៀបចំរបាយការណ៍ជាភាសាខ្មែរនិងបញ្ចូលទិន្នន័យទៅក្នុងឧបករណ៍អេឡិចត្រូនិចដូចជា Tablets
- មានបទពិសោធន៍គាំទ្រ ឬ ផ្តល់ការបណ្តុះបណ្តាលសកម្មភាពកសាងការយល់ដឹងសៀវភៅណែនាំស្តីពីប្រតិបត្តិការសហគមន៍ដើម្បីឱ្យយល់ច្បាស់អំពីការរៀបចំ និងអនុវត្តគម្រោង។

II. **អាសយដ្ឋាននៃការដាក់សុំដាក់ពាក្យ**

បេក្ខជន - បេក្ខនារីដែលមានចំណាប់អារម្មណ៍អាចដាក់ប្រវត្តរូបសង្ខេបជាភាសារខ្មែរ ឬអង់គ្លេស នៅសាលាឃុំគោលដៅខាងលើ ឬសាលាខេត្តសៀមរាប ឬអាចផ្ញើរមកការិយាល័យសម្របសម្រួលគម្រោង (PCO) ផ្ទាល់ ឬតាមរយៈសារអេឡិចត្រូនិក (Email: heanhbunna@gmail.com) រាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះ **ឈប់ដល់ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង១៦ និង ៣០នាទី** ជាកាលបរិច្ឆេទចុងក្រោយ ឈប់ទទួលពាក្យ ។

ចំពោះព័ត៌មានផ្សេងៗទៀត បេក្ខជនអាចទំនាក់ទំនងនៅក្រសួងមហាផ្ទៃ #២៧៥ មហាវិថីព្រះនរត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន **តាមរយៈទូរស័ព្ទលេខ ០១២ ៥០៤ ៧១១** រៀងរាល់ម៉ោងធ្វើការ ។

ថ្ងៃសុក្រ ៧ កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១៨

**ប្រធានគ្រប់គ្រងគម្រោងថ្នាក់ជាតិ**

**ប៊ុត ឌិ**

**ចម្លងជូន**

-សាលាខេត្តសៀមរាប
-សាលាស្រុក ០៩
-សាលាឃុំ ១៨
-មន្ទីរអង្គភាពជុំវិញខេត្ត
«ដើម្បីជ្រាប និងផ្សព្វផ្សាយ»
-ឯកសារ